កិច្ចសម្ភាសលោកយាយ សំ យ៉ុម

កៈ អ្នកសម្ភាសនឈ្មោះហេង សុជីវី ខៈ អ្នកត្រូវគេសម្ភាសឈ្មោះ សំ យ៉ុម

កៈ ចាសជំបូងជំរាបសួរយាយ !

ខៈ អឺ ...!

កៈ
ចាសលោកយាយថ្ងៃនេះដែរចៅមកពីខាងស្ម័គ្រចិត្តរបស់ខាងគំរោងរបស់សាលាBYUនៅសហរដ្ឋអាមេរិកហើយគំរោងមួយនិងចង់ជួយចងក្រងពង្សប្រវត្តិរបស់ប្រជាជនកម្ពុជាដែលគាត់មានវ័យចាប់ពីអាយុ៣៥ឆ្នាំឡើងទៅនិយាយពីជីវិតរបស់គាត់ !

ខៈ អូ...ចៅហើយយាយកាលនោះវេទនាខ្លាំងណាស់ចៅតាំងពីជំនាន់ឥស្សរតាំងស្អីពីមុនចូលនេះទៀតណាចៅអើយ សំណាងណាស់បានរស់ប៉ុណ្ណឹងណា!

កៈ ចាសត្រូវហើយលោកយាយ
ចាសអឺ...គំរោងមួយនិងអញ្ចឹងគឺគេចង់ចងក្រងពង្សប្រវត្តិរបស់លោកយាយពីមុនដែលលោកយាយធ្លាប់បានឆ្លងកាត់និងហា កុំឲ្យមានការបាត់បង់ណាយាយ!

ខៈ ចាស!

កៈ ចាស
ហើយអញ្ចឹងជាជំបូងនៃការសម្ភាសតើលោកយាយអនុញ្ញាតិឲ្យចៅយករូបរបស់លោកយាយនិងសំលេងរបស់លោកយាយយកទៅដាក់ក្នុងវែបសាយ
ដើម្បីទុកឲ្យកូនចៅរបស់លោកយាយជំនាន់ក្រោយបានស្តាប់ដែរឬទេលោកយាយ?

ខៈ ចៅឯងនិយាយតិចៗអញ្ចឹងយាយស្តាប់មិនបានទេ!

កៈ អញ្ចឹងហ៎លោកយាយចាសអញ្ចឹង?

ខៈ យាយថ្លង់ណាស់ចៅ!

កៈ ចាសអញ្ចឹងចៅសុំខឹងឲ្យក្បែរលោកយាយបន្តិច យាយអញ្ចែក
ចៅថ្ងៃនេះមកទីនេះមកដើម្បីសម្ភាសន៍លោកយាយ ដើម្បីជួយចងក្រង ពង្សប្រវត្តិ

ព្រមទាំងប្រវត្តិយាយទាំងប៉ុន្មាន
ហើយបទពិសោធន៍ដែលលោកយាយធ្លាប់ជួបនិងឆ្លងកាត់ពីមុនមកអញ្ចឹងណា!

ខ៖ ចាស!

ក៖ អញ្ចឹងលោកយាយអនុញ្ញាតិឲ្យចៅបានថតសំលេងរបស់យាយបានដែរឬទេ?

ខ៖ ចាសបានចៅ ថតចុះចៅធ្វើមិចក៏បានដែរ!

ក៖ អឺ...ចាស!

ខ៖ យាយគ្មានឃាត់ទេ!

ក៖ ចាស អញ្ចឹងលោកយាយថ្ងៃនេះជាថ្ងៃទី២០ អឺ...ការសម្ភាសនិងថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៨!

ខ៖ ឥលូវនិងទី២៤ហើយចៅ?

ក៖ ចាសយាយ!

ខ៖ មកពីយាយមិនដឹងថ្ងៃ ដឹងអីទៀត ថ្ងៃសីលគេមិនដឹងថាថ្ងៃសីលទៀតចៅឯងគិតមើល ទាល់តែយាយៗមកហៅ!

ក៖ អឺ...!

ខ៖ យាយភ្លេចគ្មានដឹងអីទេ ហើយមិនដឹងចៅឯងសម្ភាសកើតមិច!

ក៖ ចាសហើយលោកយាយមានឈ្មោះអីដែរយាយ?

ខ៖ ឈ្មោះថាយាយ សំ យ៉ុម!

ក៖ អឺ...ចាសលោកយាយនាមត្រកូល
របស់លោកយាយត្រូវជាមួយអត្តសញ្ញាណប័ណ្ណដែរឬទេយាយ?

ខ៖ អត់អីចៅទាល់តែមើលសិន!

ក៖ ចាសយាយមានអត្តសញ្ញាណប័ណ្ណដែរឬទេយាយ?

ខ៖ នៅឯណាទេ រកឃើញមិនឃើញទេចៅ!

កៈ ចុះយាយទៅបោះឆ្នោតដែរទេយាយ?

ខៈ យាយទៅ!

កៈ ចាសយាយពលរដ្ឋល្អយើងត្រូវទៅបោះឆ្នោត!

ខៈ “២:១”!

កៈ យាយមានលិខិតឆ្លងដែនទៅអាមេរិកទៀតហ៎លោកយាយ?

ខៈ អត់ទៅទេឈប់ទៅហើយរងារណាស់ចៅអើយយាយទើបតែមកនិង!

កៈ អញ្ចឹងហ៎យាយ!

ខៈ រងារនៅមិនបានទេចៅ !

កៈ យាយទៅនិងធ្វើអីគេទៅលោកយាយ?

ខៈ កូនខ្ញុំមកយកយាយទៅ!

កៈ អញ្ចឹងហ៎? គាត់រស់នៅរដ្ឋណាដែរលោកយាយ?

ខៈ នៅអីគេទេរងាចង់ងាប់ស្អីទេមិនដឹងរដ្ឋអីទេភ្លេចបាត់ហើយ!

កៈ កាលនិងគាត់ធានាលោកយាយទៅប៉ុន្មានខែ ប៉ុន្មានឆ្នាំដែរទៅយាយ?

ខៈ យាយទៅបានទេពីរខែ ឥលូវឲ្យទៅទៀតហើយ ហើយចៅទើបឡើង
យន្តហោះថ្ងៃទី២២និងដែរគេហៅទៅដែរតែយាយមិនទៅទេចៅ យាយលែងចង់ទៅហើយ
នៅវត្តនេះបានហើយចៅ!

កៈ អឺ...(សើច)ហ្នឹងហើយយាយមកពីរងារពេក!

ខៈ ចាសចៅរងារណាស់លោកអើយ!

កៈ តែគេមានម៉ាស៊ីនកំដៅអីដែរតើលោកយាយ?

ខៈ ថីមិនមានចៅអើយតែដេកមិនលក់
ពេលអត់ដេកដើរមើលគេតាមកញ្ចក់និងឯងគេទៅស្ងាត់!

កៈ អឺ....មកពីយាយមិនចេះនៅនិងអញ្ចឹង!

ខ៖ ឲ្យយាយចេះនៅមិចបើមិនដឹងថ្ងៃសីលថ្ងៃអីផង ទាល់តែប្អូនវាគេទូរស័ព្ទពីនេះទៅ
ថាបងអើយថ្ងៃនេះថ្ងៃសីល
យាយអត់មានដឹងអីបន្តិចអត់វត្តណាអីណាពីណាគេជូនឯងទៅទេណាចៅ ពិបាកណាស់ចៅ!

ក៖ អឺ...ចាសលោកយាយ!

ខ៖ នៅនេះមួយពាន់អីដាក់បាតលោក(ព្រះសង្ឃ)បានណា!

ក៖ ចាសនិងហើយយាយ!

ខ៖ នៅនេះមានលុយតែពីរពាន់អីទិញបបរស៊ីបានណាចៅ!

ក៖ ចាសយាយ!

ខ៖ នៅនោះមិនងាយរកទេចៅទាល់តែគេជូនឡានទៅផ្សារទៀតន៎!

ក៖ ចាសយាយ(សើច)!

ខ៖ ទិញហើយទាល់តែដឹងដាក់រទេះរុញដាក់ឡានមក
ដាក់ឥវ៉ាន់ម្តងទុកស៊ីមួយអាទិត្យបើត្រីវិញរឹងដូចថ្មរអញ្ជឹងចៅ!

ក៖ ចាសនិងហើយមកពីវាត្រជាក់!

ខ៖ នាងហើយនាងកុំចង់ស៊ីអីនំគ្រក់ តែប៉ុណ្ណឹង៥ដុល្លា
ចេកចៀនម៉ាស្និតប្រាំដណ្តប់ដុល្លា(១៥ដុល្លា)

និងចេកម៉ាស្និតណាចៅ អត់មានចេកទេ ខ្ទុរមួយតែប៉ុណ្ណឹងទេណា៧០ដុល្លា
កុំចង់រកស៊ីអីអត់បានទេខ្ជិលណាស់នៅស្រុកយើងទិញតែបីពាន់ពីរពាន់បានស៊ីហើយ!

ក៖ (សើច) ចាសតែនៅនិងប្រាក់ខែគេក៏ថ្លៃដែរលោកយាយ!

ខ៖ អត់ទេកូនខ្ញុំវិញចង់ឲ្យម៉ែនៅទៅបានប្រាក់ខែ
បើរងាៗចង់ងាប់យ៉ាងនេះប្រហែលខ្លាចងាប់ចោលមិនបានស៊ីទេចៅ!

ក៖ (សើច)!

ខ៖ រងារពេកស៊ីបាយមិនបានទេរងារពេកណាចៅរងារណាស់!

ក៖ ចុះលោកយាយ?

ខ៖ ហ្អាស?

ក៖ បងប្អូនលោកយាយដែលនៅនិងគាត់ជាកូនរបស់លោកយាយផ្ទាល់ឬយ៉ាងមិច?

ខ៖ ចាសជាកូនខ្ញុំផ្ទាល់ កូនបង្កើត កូនប្រុសបន្ទាប់មក
វាមកលេងខែ១២នេះមកលេងយាយហើយ!

ក៖ អឺ...ចាស!

ខ៖ មីថៅយាយមួយឡើងយន្តហោះថ្ងៃ២២ទៅ គេមានប្តីគេអាមេរិកកាំខ្មៅអូច!

ក៖ អឺ...(សើច)!

ខ៖ រិះម៉ែអារិះ!

ក៖ កាត់ខ្មែរមែនទេយាយ?

ខ៖ មែនមកអីជូនយាយ៥រៀល(ដុល្លា)ឬមួយរៀល(ដុល្លា)អត់ផងគំរិះណាស់អាមេរិកកាំងនេះ!

ក៖ (សើច)យាយមិចចឹងប្រហែលដោយមនុស្សទេដឹងយាយ?

ខ៖ អឺ...ថៅ!

ក៖ និងហើយប្រហែលដោយមនុស្សទេលោកយាយ ហើយកូនរបស់យាយ
គាត់ទៅនិងអាមេរិកនិងទៅធ្វើអីដែរលោកយាយ?

ខ៖ កូនខ្ញុំធ្វើការថៅខ្ញុំធ្វើការងារខាង យន្តហោះ
អាមួយប្រុសរកបានមួយម៉ោង២៥ដុល្លានិងអាកូន បើអាឪវាធ្វើការមួយម៉ោងបាន១៧ដុល្លា
មីប្រពន្ធគេធ្វើការងារបានទៀតនិយាយទៅវាធ្វើការងារទាំងអស់គ្នាណាថៅ
ពេលអុំទៅនៅតែម្នាក់ឯងទេ ខ្យល់ចាប់ម្តងៗកោសតែម្នាក់ឯងទេខ្ជិលណាថៅ!

ក៖ (សើច)!

ខ៖ នាងហើយនាងកុំចង់ទៅនៅហ៎ដូចយាយនៅនិងមិនបានទេ!

ក៖ (សើច)

ខ៖ យាយមិនចេះនៅទេថៅ!

ក៖ មកពីកាលហ្នឹងយាយទៅចំពេលគេត្រជាក់និងណាយាយ(មានសំលេងរំខានពីខាងក្រៅ)!

ខ៖ អឺ....!

ក៖ គេមានខែក្ដៅគេដែរនិងលោកយាយ!

ខ៖ អឺ...!

ក៖ កាលនិងយាយទៅលេងយូរដែរទេរយៈពេលប៉ុន្មានដែរយាយ?

ខ៖ កាលហ្នឹងយាយទៅលេងពីរខែដែរ!

ក៖ អឺ...ចាសលោកយាយ!

ខ៖ យាយសុំគេនៅនិងតែពីរខែទេចៅ!

ក៖ ទៅចំខែណាដែរយាយ?

ខ៖ យាយទាមកវិញហើយ
គ្រាន់តែយាយជិះកប៉ាល់ហោះយាយសំយ៉ុងជើងហើមជើងចង់ងាប់!

ក៖ អឺ...ចាស!

ខ៖ ពិបាកណាស់នាងអើយមិនមែនស្រួលទេ
ឥលូវគេហៅឲ្យទៅគេម៉ៅអាគ្រែដេកគ្រែអីតែយាយមិនទៅទេចៅអើយ!

ក៖ អឺ...ចាស!

ខ៖ យាយអង្គុយងាកតែខ្លួនមិនរួចនិងចៅ
មែនដូចយើងស្រួលទេចៅ(មានសំលេងរំខានពីខាងក្រៅ)!

ក៖ អឺ...ចាសយាយ!

ខ៖ ដល់ឯងនេះទឹកនោមផ្អែមតិចឈឺនោមៗ ដើរក៏ពិបាកដើរដែរចៅ!

ក៖ (សើច)!

ខ៖ពិបាកណាស់ចៅអើយទោះយ៉ាងណាក៏មិនអាចដូចស្រុកយើងដែរណាចៅ!

ក៖ ចាសហ្នឹងហើយលោកយាយ!

ខ៖ បើក្មេងៗគេទៅបានព្រោះគេទៅរកលុយរកអីធ្វើការណាចៅតែយើងនេះ ម៉ែចាំបើកប្រាក់ខែម៉ែកុំអាលទៅៗចុះឈ្មោះចុះអីសិនទៅទេមិនបាច់ទេ សង្ស័យងាប់មុនប្រាក់ខែនិងហើយមិនបាច់ទេកូន!

ក៖ (សើច)!

ខ៖ (សើច)!

ក៖ (សើច)!

ខ៖ នៅទៀតរស់មិនបានទេចៅបើរងារយ៉ាងនេះៗចៅ!

ក៖ ចាសយាយ អញ្ចឹងកូនរបស់លោកយាយនៅអាមេរិកនិងគាត់ធ្វើការខាងយន្តហោះន៎យាយន៎!

ខ៖ ចៅខ្ញុំ!

ក៖ ចៅទេន៎លោកយាយ!

ខ៖ អាឪកូនខ្ញុំវាមើលផ្ទះវាមើលផ្ទះដូចអាផ្ទះណាមានគេជួលម៉ាស៊ីនទឹកខូចទៅ មានអាស្ទីខូចគេជួលជុលទៅណា!

ក៖ ចាស!

ខ៖ អាចៅនិងវាធ្វើការនៅខាងរៀបខ្មៅកប៉ាល់ហោះ(យន្តហោះ)!

ក៖ អឺ...ចៅលោកយាយធ្វើខាង!

ខ៖ ចៅកូនអាហ្នឹងហ្អាស!

ក៖ អឺ...!

ខ៖ និងហើយ!

ក៖ គាត់ធ្វើខាង ហ្វីឡុត ខាងបើយន្តហោះ?

ខ៖ ហ្អាស??

ក៖ ខាងបើកយន្តហោះនិងមែន?

ខ៖ អត់ហ្អែស មូលខ្មៅមូលខ្យងអីនិងណា!

ក៖ អឺ...ចាស!

ខ៖ ខ្មៅកប៉ាល់ហោះ(យន្តហោះ)សុទ្ធជ័រ!

ក៖ អឺ...!

ខ៖ អាចៅខ្ញុំវាថាយាយខ្ញុំមិនហ៊ានជិះយន្តហោះទេខ្លាចណាស់សុទ្ធតែជ័រ!

ក៖ (សើច)! ហើយចុះយាយមានបងប្អូននៅស្រុកគេប៉ុន្មាននាក់ទៀតដែរយាយ?

ខ៖ គ្មានទេ!

ក៖ មានតែកូន?

ខ៖ មានតែខ្ញុំម្នាក់ឯង អត់មានបងបងប្អូនសោះហើយ!

ក៖ អឺ...!

ខ៖ ចាប់សំភាសន៍ទៅចៅថាអីទៀត?

ក៖ ចាសយាយអញ្ចឹងលោកយាយសព្វថ្ងៃអាយុប៉ុន្មានហើយយាយ?

ខ៖ ខ្ញុំហ្អែស?

ក៖ ចាស!

ខ៖ អ្នកណា?

ក៖ លោកយាយម៉ងអាយុប៉ុន្មានហើយ?

ខ៖ ៨៥ឆ្នាំខ្ញុំអាយុ៨៥ឆ្នាំ!

ក៖ ឆ្នាំអីគេលោកយាយ?

ខ៖ ឆ្នាំចនិងអាយុ៨៥ឆ្នាំហើយ ខ្ញុំកើតឆ្នាំចនិងដែរ!

ក៖ អូ...ល្អណាស់!

ខ៖ បងសម្តេចឪមួយជូរ!

កៈ អឺ...អញ្ចឹងយាយកើតនៅក្នុងខែឆ្នាំណាដែរយាយ?

ខៈ កើតថ្ងៃព្រហស្បត៍ ខែពិលាខខ្ញុំ!

កៈ អឺ...ចាស!

ខៈ ឆ្នាំច ថ្ងៃព្រហស្បត៍ ខែ ពិសាខ!

កៈ ចាសលោកយាយ ហើយយាយមានស្រុកកំណើតនៅណាដែរ?

ខៈ ស្រុកកំណើតនៅនិង ដូនតាមកនៅនិងដីធ្លីគេយកអស់ គ្មានយកអីបានហ្មេស!

កៈ (សើច)!

ខៈ មកពីអាពតមិនទាន់គេទេ!

កៈ អូ...សោកស្តាយយាយណា!

ខៈ គ្មានបានអីទេនាងហើយ!

កៈ សារនិងបែកមកទាំងអស់គ្នានិងនណាគេក៏អញ្ចឹងដែរយាយ!

ខៈ ដល់មកសុំវត្តនៅតូបគេទៀតណា ដល់ឯងអាដែងទៅអាមេរិកពីរខែមកវិញគេមិនចេញ រួចខ្ញុំនៅផ្ទះខ្ញុំវាមិនបាន នៃផ្ទះថ្មរលីកទឹកនិង កូនណក!

កៈ អឺ...!

ខៈ ទឹកលិចត្រឹមណាណឹនៅខាងលិចវត្តនិងនាង ដល់ខ្ញុំនៅវាមិនកើត!

កៈ ចាសយាយ! អញ្ចឹងតូបលោក(ព្រះសង្ឃ)យាយនៅទេ?

ខៈ មកសុំគេ គេធ្វើម៉ែគេងាប់អស់បីនាក់ហើយតាំងពីធ្វើមក
នេះរូបថត!គ្រាន់តែសុំគេនៅព្រោះគេទុកចោល!

កៈ អឺ...!

ខៈ ខ្ញុំគ្រាន់តែសុំគេនៅបណ្ដោះអាសន្នគ្រាន់ងាប់ទេ (ស្តាប់មិនបាន)ក្នុងនិង!

កៈ អឺ...!

ខៈ នៅយូរបន្តិចចុះ!

កៈ អឺ...ហើយលោកយាយមកនៅនេះប៉ុន្មានឆ្នាំហើយ?

ខៈ ខ្ញុំមកពីអាពតមកនៅវត្តនេះរហូត ខ្ញុំអត់រកស៊ីអីទេ ខ្ញុំទឹម
ថានៅវត្ត(ស្តាប់មិនបាន៨:៥០)រួចទៅខ្ញុំមកវិញព្រោះខ្ញុំនៅផ្ទះមិនបានទឹកលិចពេក!

កៈ អឺ...ចាស!

ខៈ នៅតាំងពីព្រៃជុកសាលាចាស់អីមួយថ្ងៃៗធ្វើគ្មានឈប់ទេ!

កៈ អឺ...!

ខៈ នៅស្មៅបន្លារជូនអាសង្គ័សីអាពតជូនជញ្ជូនទៅក្រវែងចោល ហើយអ្នកមកនៅវាដាំអំពៅ
វាចិញ្ចឹមជ្រូក ឯងឯណេះទៅទូលអានេះអានោះយកមកផ្សំ
សង់ធ្វើរោងបានរោងអីអាចាស់តែឥលូវរុះអស់ហើយ!

កៈ អឺ...ចាស! ចុះក្រុមគ្រួសារលោកយាយវិញលោកយាយ?

ខៈ ងាប់និងអាពតអស់ហើយ!

កៈ ទាំងអស់គ្នាម៉ងហ៎ លោកយាយ?

ខៈ បែកគ្នា!

កៈ អញ្ចឹងកាលនិងគេជំលៀសទាំងក្រុមគ្រួសារលោកយាយទៅណាដែរ?

ខៈ គ្រួសារខ្ញុំមិនដឹងគេទៅណាទេគេទៅមុនខ្ញុំ ដល់ខ្ញុំទៅក្រោយ
ខ្ញុំអាលែងរត់ទៅន៎ឯងសាលារៀនបាក់ទូកហ៎ អាប្តីនិង ប្តីខ្ញុំនៅផ្ទះ
រួចដល់មិនដឹងអាពតយកទៅណាទេមកវិញរកមិនឃើញ បែកគ្នាទៅ!

កៈ អឺ...!

ខៈ មិនដើររកនៅណា!

កៈ អញ្ចឹងអត់ដែរស្វែងរកគ្នាទេលោកយាយន៎ ?

ខៈ អត់រកគ្នាឃើញទេមិនដឹងទៅរកឯណា!

កៈ ដែលប្រកាសស្វែងរកបងប្អូនអីដែរទេលោកយាយ?

ខៈ អឺ...មានតែអាពតវៃចោលវាមិនដែលប្រកាសទៅណាទេ!

កៈ
អឺ...ចុះលោកយាយឃើញនិងភ្នែកដៃរទេកាលនិងបានជាលោកយាយដឹងថាគេយកទៅវៃចោល?

ខៈ អត់ឃើញហ្អេ!

កៈ លឺគេប្រាប់មែនទេលោកយាយ?

ខៈ ប៉ុន្តែរមនុស្សសអញ្ចឹងវាច្រលំស្មានតែយួនទៀតណា អាពតនិង!

កៈ (សើច)!

ខៈ វាមិនទុកយើងទេ!

កៈ អឺ...!

ខៈ ចៅអើយ!

កៈ អញ្ចឹងគេប្រើយាយធ្វើអីខ្លះជំនាន់អាពតនិង?

ខៈ អឺ...ចៅហើយចៅ រកតែអីស៊ីមិនបានគ្មានអង្ករមួយកាប៉ុងផងម៉ារយនាក់ម៉ាគ្រាប់ពីរគ្រាប់ពិបាកបែងចែកណាស់ បើក្មេងៗវិញវាយំរកតែម៉ែទេ ហើយមកទូលអង្ករ លុយទឹកទូលអង្ករតាំងពីមាត់ស្ទឹងយកទៅបបរ វាយើងដក ឲ្យយើងគាស់គល់ធំៗនិង ហើយឯងមានកំលាំងឯណាគាស់!

កៈ ចាស់យាយ!

ខៈ អត់បាយស៊ីផង ស៊ីតែស្លឹកឈើស៊ីតែស្លឹកស្ទឹងស៊ីតែជើងចាប់អីនិង ជ្រលក់អំបិលស៊ី ហើយគល់អីនិងអ្នកគេដាំទៅគាស់មានផ្លែរយកមក កាប់យកអាខ្ចីៗកណ្តាល!

កៈ អឺ...!

ខៈ ជ្រលក់អំបិលស៊ីទៅ!

កៈ ចាស់យាយ!

ខៈ មែនស្រួលទេចៅវេទនាណាស់ ហើយវាចែកអង្ករឲ្យវិញវាចែកស្រូវម៉ាកាប៉ុង យាយ កូនយាយមានបីនាក់យាយម្នាក់ទៀតបួនស្រូវម៉ាកាប៉ុងយកមកលីងទាំងលាជទាំងអីនិងបុក

ហើយហៅកូនមកជុំគ្នាចែកគ្នាអានេះបីស្លាព្រា អានោះបីស្លាព្រាៗ សល់ប៉ុន្មានស៊ីខ្លួនឯងទៅ អញ្ចឹងហាស រួចបើកល្ហុង ដំឡូងវាគាស់ទាំងរទេះ...ទាំងរទេះអាដំឡូងឈើនិង ដំឡូងមីនិងវាកាប់ម៉ាកង់ៗទៅចែកស៊ីចង់ងាប់ នៅតែថ្ងៃងាប់ទេស្វិតអស់ហើយគ្មានដោះគ្មានអីទេហើយស្គមដើរអត់រួចទេ !

កៈ អឺ...!

ខៈ នាងហើយអ្នកខ្លះដេកងាប់ទៅ អាខ្លះអីទៅ អាខ្លះថ្ងូរឃ្លានបាយណាស់ៗភ្លឺឡើងដាច់ខ្យល់!

កៈ អឺ...!

ខៈ (ស្តាប់មិនបាន) មិនដូចថៅឯងកើតឥលូវនេះមិនអីទេ!

កៈ អឺ...!

ខៈ រកអីស៊ីមិនបានទេថៅអើយ មិនមែនទៅដេក ដឹងយើងទៅទាំងរទេះភ្លើង ...ទាំងរទេះភ្លើងមិនមែនមានផ្ទះឲ្យយើងនៅទេ ទៅធ្វើខ្ទមធ្វើអីក្នុងព្រៃនិង យប់ឡើង ភ្លឺឡើងកូនរឹងស្អួកក្បែរមាត់ទឹក វាត្រជាក់វាមិច ចាញ់ស្រុក យាយទៅដេកក្បែរមុងខ្មោចគេនិង អាខ្មោចវាងាប់៧ខែក្នុងពោះនិង!

កៈ អឺ...!

ខៈ ហើយអាកូនពៅនោះវានៅតូច អាកូនពៅឆ្នាំឆ្លូវសព្វថ្ងៃនិង តែឥលូវវាទៅជប៉ុន!

កៈ អឺ...!

ខៈ ដល់ពេលអញ្ចឹងទៅ ខ្មោចនិងវាលងវាចេះតែយំ ចេះតែសូត្រធម៌ពុលជើងក្អែក ហើយសូត្រធម៌ពុសជើងក្អែក ភ្ញាក់ឡើងជិតអាម៉ុងខ្មោចនិង អាម៉ុងខ្មោចគេដាក់ជិតដើមត្នោតដែលគេកប់និង ឯងវាដើរដេកពេលយប់ទៀតហ៎ក្រាលស្លឹកឈើអីបើមានកន្ទេលទៅក្រាលទៅ!

កៈ អឺ...!

ខៈ មិនមែនស្រួលទេ!

កៈ អ៎...អូលោកយាយកាលហ្នឹងពិបាកណាស់ ហើយនិយាយទៅកាលនិងគេធ្លាប់ធ្វើបាបលោកយាយដែរទេ កាលពីជំនាន់ប៉ុល ពតនិង?

ខ៖ ខ្ញុំនៅសារនិង អាយុ៥៥ឆ្នាំ ជំនាន់អាពត!

ក៖ អឺ...ចាស!

ខ៖ ដល់អញ្ចឹងថៅឯងគេឲ្យទៅច្រូតស្រូវអញ្ចឹងទៅ ហើយយើងទៅគរកណ្តាប់
គរៗពូកៗលើអាទះគេដឹក អាពស់ៗក្រលាកន្ទេលហ្មាស វានៅមូលនៅនិងណា
រៀងតែមិនមើលឲ្យស្រួលទេចឹងងាប់តែម្តង អាពស់ ពស់ពភ្លាក់អីនិង!

ក៖ ពស់ក្រលាកន្ទេល?

ខ៖ និងហើយ អាដូចក្រលាកន្ទេលខ្លីៗប្រវែងៗនេះចឹកដូលងាប់ ចឹងងាប់ ថៅខ្ញុំមួយ
ក្មួយខ្ញុំមួយងាប់ដែរ ទៅដល់ពោធិសាត់អត់អីដេក ក្រាលអាសង្កសីដេកក្នុងព្រៃនិង
យប់ឡើងវាចឹងដល់ព្រឹកឡើងងាប់គ្មានដឹងអី!

ក៖ អឺ...!

ខ៖ ហើយវេទនាណាស់ថៅៗបានសំណាងហើយមកកើតជំនាន់នេះ
ថ្មីៗកាលនៅអាពតនោះបើនៅជំនាន់អាពត ប្រហែលជាអត់រស់ទេ កូនខ្ញុំអត់មានអត់ទេ
បើអត់អីស៊ីកូនបានអីបៅ!

ក៖ និយាយរួមកាលនិងវាពិបាកណាស់!

ខ៖ ងាប់!

ក៖
ហើយយាយកាលលោកយាយមិនបានពិសារអីគ្រប់គ្រាន់កាលហ្នឹងលោកយាយធ្លាប់ឈឺដែរឬ
ទេកាលហ្នឹង!

ខ៖ឈឺណាថៅទៅសុំថ្នាំវាៗឲ្យអាថ្នាំអីខ្មៅៗដូចអាចម៍ហើយតូចៗប៉ុណ្ណឹងវាឲ្យលេប!

ក៖ ហើយបាត់ដែរទេយាយ!

ខ៖ យើងចេះតែរាគអាចម៍ ហើយអាស្អីបុកអង្កនិងទៀត ហើយដើរតាមផ្លូវក៏ បេះស្លឹកសាវម៉ាវ
ស្លឹងគរ ស្លឹកអីចេះតែច្របាច់ទៅ ហើយបបរវាចែកឲ្យតែមួយវែកប៉ុននេះទេ
កាលនិងដឹងអាទះភ្លើង !

កៈ អឺ...ចាសលោកយាយអញ្ចឹងកាលនិងដូចជាលោកយាយបានពិសារ
អីអត់គ្រប់គ្រាន់អីអញ្ចឹង ដូចជាឈឺអញ្ចឹងលោកយាយមានធ្លាប់គិតថាចង់ដាច់សម័យ ប៉ុល
ពតនិងភ្លាមៗដែរទេកាលជំនាន់និង?

ខៈ អើយចៅអើយយាយថាយាយមិនរស់ទេ អាគល់ឈើប៉ុននេះ
យើងដើរទាល់តែលើកដាក់ទៅមុនបានដើររួចទំរាំលើកជើង កន្លងគល់ឈើនិង!

កៈ អឺ...!

ខៈ បេះកំពឹងពួយស៊ីបេះអីស៊ីនិង ជីកទំពាំងយកមកស្ងោរស៊ីដូចបាយ ហើយវាមិនឲ្យជីកទៀត
ហើយសូម្បីតែត្រកួនក្បែរអាចម៍គោអីនិងយើងដើរបេះក៏វាមិនឲ្យផង!

កៈ អឺ...!

ខៈ ថាយើងនិង នៅភ្នំពេញគេថាស៊ីបរបូរហើយហើយអាក្មេងប៉ុននេះនិង!

កៈ អឺ...ចាស!

ខៈ ហើយត្រីអន្លុងវា សុំមកយាយឯងធ្លាប់ហូបហើយមិនបាច់ឲ្យទេ!

កៈ អឺ...!

ខៈ សម័យអាពតនិង!

កៈ ចាសយាយ
ហើយចុះកាលហ្នឹងយាយធ្លាប់ឃើញអាពតយកមនុស្សទៅសម្លាប់ចោលនិងភ្នែកអត់យាយ?

ខៈ ដូចប្រែតទាំងរស់ហើយសព្វថ្ងៃនិង កាលនៅនិងហ៎!

កៈ អញ្ចឹងយាយធ្លាប់ឃើញប៉ុល ពតយកមនុស្សទៅសម្លាប់ចោលនិងភ្នែកយាយដែរទេ?

ខៈ យាយអត់ឃើញទេគ្រាន់តែគេចងអញ្ចែក
ហើយវាបណ្ដើរទៅនិងមុខយើងក៏មិនហ៊ានមើលដែរ! អត់ទៅមើលផងទេ យើងហ៊ានមើលទេ!

កៈ អឺ...!

ខៈ ហើយពួកនិស្សិតនារីដូចនាងឯងអីនិង វាឲ្យទៅធ្វើស្រូវឆ្ងាយ
ដល់មកវិញទឹកវាជន់ទៅអាអណ្ដូងវាជីកប៉ុនៗនេះ ដើរមានដឹងអណ្ដូងអីមិនធ្លាក់អណ្ដូងងាប់!

កៈ អឺ...!

ខៈ វេទនាណាស់ចៅណា!

កៈ ហើយកាលនិង!

ខៈ មានពេជ្រអីដូរអង្ករក៏ដូរដែរ!

កៈ ចាសយាយ!

ខៈ ចប់អាពតទៅវាមិនចេះប្រើពេជ្រនិងទេ ប្រើតែមាស!

កៈ អឺ...!

ខៈ ដូរមួយជីទៅបានល្មូង ប៉ុននេះមួយ បានស្លឹងគ្រែបន្តិចនិង
ហើយជូនណាបានជំឡួងមួយគីឡូ ដើរដូរតាមផ្លូវ ដល់ទៅដល់ភូមិនោះអត់មាន
អញ្ចឹងហើយមាសវាចុះថោក!

កៈ ចាស កាលនិងមាសមិនសូវមានតម្លៃ!

ខៈ វាសម្បូរណាស់សម័យអាពតនោះ!

កៈ ចាសយាយ កាលមុនគ្រួសាររបស់លោកយាយ ដូចជាម៉ាក់របស់លោកតា លោយាយ
លោកតាដែលត្រូវជាឪពុកម្ដាយលោកយាយគាត់ឈ្មោះអីដែរ?

ខៈ អូ...យាយខ្ញុំហ្អេស? យាយខ្ញុំឈ្មោះយាយប៉ែន តាខ្ញុំឈ្មោះតាម៉ៅ
តែខ្ញុំមិនដឹងនាមត្រកូលគាត់ស្អីទេ បើកើតមកមិនទាន់ដែរ កើតមកគាត់អាយុ ៨៥
ទៅ៨៣ហើយ ខ្ញុំអាលែងតែទៅតាមជីដូនខាងម្ដាយឪពុក ជីដូនខាងម្ដាយដណ្ដើមជីដូនខាង
ឪពុកនិងយកទៅ យាយស្លាប់ខ្ញុំមិនដឹងផង ព្រោះឯងតែម្នាក់ឯងកើតតែម្នាក់ឯងមួយមុនគេ!
ឪពុកធ្វើទាហ៊ានស្លាប់ទៅឪពុកនិង !

កៈ អឺ...!

ខៈ ម្ដាយស្លាប់មុនទាហ៊ាននិងទៅទៀត !

កៈ អឺ...!

ខៈ ខ្ញុំអាយុបីឆ្នាំម្ដាយខ្ញុំស្លាប់!

កៈ អឺ...!

ខៈ បាន៧ទៅ៨ឆ្នាំបានឪពុកទៅធ្វើទាហ៊ាន រាំងជើងក្រហមនិង
ប៉ារេក្រហមទៅគេបញ្ជូនទៅកំពង់ចាម!

កៈ អឺ...ចាស!

ខៈ វេទានណាស់ចៅ!

កៈ ចុះឪពុកម្ដាយរបស់លោកយាយមានឈ្មោះអីដែរ?

ខៈ ឪពុកខ្ញុំឈ្មោះ សំ ម៉ែខ្ញុំឈ្មោះគាំ គាត់ឈ្មោះ ម៉ៅ គាំ!

កៈ ចាសយាយ!

ខៈ ឪពុក ឈ្មោះច សំ !

កៈ ចាស ហើយគាត់មានកូនប៉ុន្មាននាក់លោកយាយ?

ខៈ មានតែមួយនិង!

កៈ មានតែមួយនិងទេលោកយាយ បានតែមួយ!

ខៈ គ្មានបងគ្មានប្អូនទេ(ស្ដាប់មិនបាន)!

កៈ ចុះលោកយាយដូចជាឪពុកម្ដាយ លោកយាយលោកតាត្រូវជាឪពុកម្ដាយ
ដែលជាជីតាខាងឪពុកលោកយាយគាត់មានឈ្មោះអីដែរមុននិង?

ខៈ ឈ្មោះតា ម៉ៅ ឈ្មោះយាយ ប៉ែននិងជីតាយាយ!

កៈ ខាងម្ដាយ?

ខៈ និងខាងម្ដាយ!

កៈ ចាសយាយ!ចុះខាងឪពុកវិញយាយ?

ខៈ ខាងឪពុកវិញ យាយ យូរ តា ស!

កៈ អឺ...លោកយាយមានចង់ចាំថាគាត់បានកើតនៅក្នុងឆ្នាំណាទេ ហើយកើតនៅណាទេ?

ខៈ អូ...គ្មានចាំទេចៅអើយ ស្រុកគាត់នៅកោះឧញ៉ាតីន៎!

ក៖ អឺ...!

ខ៖ ជីតានៅខ្វរ ព្រៃកលាបយើងនិងថៅយាយមិនចាំទេ!

ក៖ គាត់មានធ្លាប់និយាយថាពេលលោកយាយកើតមកអញ្ចឹងហ្អា៎ គាត់មានប្រាប់ថាលោកយាយលោកតារបស់យាយ មានរឿងមិចគាត់មានធ្លាប់ប្រាប់ទេ!

ខ៖ អត់ទេ អត់ដែលនិយាយអីទេបើមិនសូវនៅជុំគ្នាអញ្ចឹង!

ក៖ ចាសចំណែកឪពុកម្ដាយរបស់លោកយាយវិញកាលពីមុនគាត់កើតនៅឯណាដែរ!

ខ៖ គាត់កើតនៅនិង ធ្វើស្រែ!

ក៖ នៅនិងហ៎លោកយាយ!

ខ៖ ធ្វើស្រែធ្វើអីនៅនិងភូមិនិង ដល់ឥលូវគេនៅផ្ទះថ្មរអស់ហើយ មិនដឹងភូមិអីណាទេ នៅកន្លែងវិហារចិន ពីដើមនិង!

ក៖ អឺ... នៅវត្តទឹកថ្លានិងហ៎លោកយាយ?

ខ៖ ចាសនៅវត្តនិង!

ក៖ ចុះគាត់កាលនិងឪពុកម្ដាយរបស់លោកយាយគាត់ប្រកបមុខរបរអីដែរដើម្បីចិញ្ចឹមជីវិត?

ខ៖ ធ្វើស្រែ ស្ទូងស្រូវ ស្ទូងអីនិងបេះស្លឹកឈូកអីលក់និង ចៅអើយ ព្រោះស្រុកនេះមានធ្វើស្អីមានតែធ្វើស្រែ!

ក៖ អឺ...!

ខ៖ ដកសំណាប ស្ទូង បុកអង្ករហើយបានទៅស្ទូង!

ក៖ អឺ...ចាស!

ខ៖ យើងមានម៉ាស៊ីនឯណាកិនកាលនិង!

ក៖ ហ្នឹងហើយ អញ្ចឹងគាត់ទាំងពីរនាក់ជាមនុស្សបែបណាដែរលោកយាយ?

ខ៖ ហ្អាស?

កៈ
ចង់និយាយថាឪពុកម្ដាយរបស់លោកយាយទាំងពីនាក់គាត់ជាមនុស្សបែបណាទៅលោកយាយ ដូចថា គាត់ ស្លូត កាច ឬយ៉ាងមិចដែរ មានចរិកបែបណាដែរលោកយាយមានចងចាំទេ?

ខៈ ឱចៅអើយចៅរួចចុះយាយនៅអាយុបីឆ្នាំ ឪពុកយាយធ្វើការ កន្លែងគៀនអញ្ចែក
អាបារាំងវាដាក់ៗអាដែងអង្កាំកំរងផ្កាវាប៉ុនៗនិង
គ្រប់ផ្ទះ(ស្ដាប់មិនបាន)ខាងនេះស្ពានជ្រោយចង្វារនិងណា កន្លែងនិងឪពុកខ្ញុំធ្វើការនៅនិង
ដល់ឥលូវគេរើសរុះអស់ហើយ ម្ដាយខ្ញុំធ្វើស្រែ!

កៈ អឺ...!

ខៈ ខ្ញុំក៏ទៅនៅនិងដែរ!

កៈ អឺ...!

ខៈ អានិងគេហៅពាមជរ ខ្មោចបារាំង ឪពុកខ្ញុំនៅធ្វើនៅនិង!

កៈ ចាស អញ្ចឹងលោកយាយលោកយាយបានចង់ចាំអីគេខ្លះពីឪពុកម្ដាយរបស់លោកយាយ?

ខៈ បានអីចាំៗបានតែប៉ុណ្ណឹង!

កៈ មានតែប៉ុណ្ណឹងទេយាយន៎?ហើយគាត់មានធ្លាប់ប្រាប់រឿងជីវិតលោកយាយទេ?

ខៈ ធ្លាប់ប្រាប់បើយាយអាយុបីឆ្នាំយំនោះយំ!

កៈ ចេះតែយំតាមគេ!

ខៈនិងទាស៊ីនិង!

កៈ ចាស(សើច)!

ខៈ (សើច)!

កៈ (សើច)!

ខៈ គ្មានដឹងអីទេ!

កៈ ចាសយាយ!

ខៈគ្រាន់តែដើរបេះអង្កាំអីនិង ដើរលេងនិង!

កៈ អឺ...!

ខៈ ខ្មោចបារាំង!

កៈ ពេលគាត់ស្លាប់ទៅយាយនៅជាមួយពីណាគេ?

ខៈម្ដាយស្លាប់មុននៅជាមួយឪពុក!

កៈចាសយាយ!

ខៈ ដល់ឪពុកនិងរវល់តែគេដើររវល់ទៅផឹកបាត់ទៅយំហើយយំ ប៉ាអើយៗ!

កៈ អឺ...!

ខៈ ចៅអើយវេទនាណាស់អ្នកនៅជិតខាងក៏គេដេកមិនបានដែរ?

កៈ (សើច) លោកយាយយំខ្លាំងដោយសារអត់មាននរណាគេនៅជាមួយ!

ខៈ ចាសយំរកឪពុក!

កៈ ចាសយាយ!

ខៈ គេថាដេកទៅៗ ដេកណាបើឪទៅណាបាត់ហើយ!

កៈ ហើយចុះពេលលោកយាយធំធាត់មកបានប៉ុន្មានឆ្នាំបានគាត់ចែកឋានទៅ?

ខៈ ខ្ញុំអាយុ៨ឆ្នាំគាត់ទៅធ្វើទាហ៊ាន ហើយគាត់ពិបាកគាត់ពេក
ធ្វើទាហ៊ាននៅកំពង់ចាមគាត់អ្នកផ្លុំត្រែ!

កៈ អឺ...!

ខៈ ដល់ធ្វើទាហ៊ានជាមួយទាហ៊ានជើងខ្មៅ និងទាហ៊ានជើងក្រហមមិននៅជាមួយគ្នា
ទាស់គ្នាទៀត!

កៈ អឺ...!

ខៈ ដល់ទាស់គ្នាគេបំបែកឲ្យទៅនៅខាងទន្លេរអ៊ុំ នៅខាងកើតទន្លេរអ៊ុំនិង!

កៈចាសយាយ!

ខ៖ ហើយជប៉ុនចូលមក យាយអត់មានដឹងអីទេហើយគាត់ចូលត្រង់សេ
ជប៉ុនបាញ់ងាប់អត់ដឹង ធាតុនៅឯណាទេ!

ក៖ អញ្ចឹងកាលនិងយាយអាយុប៉ុន្មានឆ្នាំយាយ?

ខ៖ អាយុធំហើយមានប្តីហើយ!

ក៖ អឺ...!

ខ៖ នៅជាមួយឪពុក!

ក៖ ចុះកាលនិងរៀបការនិងដោយសារឪពុកម្តាយជាអ្នករៀបចំឲ្យឬក៏យាយស្រលាញ់គ្នា?

ខ៖ អត់ទេ ឪពុកធំរៀបការឲ្យខ្ញុំមិនចង់យកអី!

ក៖ អ៎...!

ខ៖ បានថ្លៃផ្ទះថរយនិង គ្មានបានថ្លៃអីទេ!

ក៖ ថ្លៃជំនួនយាយនិងហ៎?

ខ៖ ចាស!

ក៖ ចាស
អញ្ចឹងលោកយាយអត់បានស្រលាញ់លោកតាទេបាននេះអញ្ចឹងក៏ដោយសារតែឪពុកធំលោក
យាយរៀបចំឲ្យអញ្ចឹង!

ខ៖ ចាស!

ក៖ ស្គាល់គ្នាពេលថ្ងៃការ!

ខ៖ និងហើយ គេអ្នកនៅក្នុងភូមិនិងដែរនៅខាងត្បូងថ្នល់និង!

ក៖ គាត់មានឈ្មោះអីដែរលោកយាយ?

ខ៖ ប្តីហ្អែស?

ក៖ ចាស!

ខ៖ ឈ្មោះ ស៊ន សៀង!

កៈ អឺ...ចាសលោកយាយ ហើយបន្ទាប់មកលោកយាយចំពោះភាសាវិញលោកយាយចេះសសេរ ចេះអានខ្មែរយើងបានល្អទេ ដែរទេយាយ?

ខៈ ថាមិច?

កៈ ចេះអានភាសារខ្មែរ លោកយាយចេះអានចះសសេរដែរទេ?

ខៈ ចេះអក្សរវគ្គ ឯងចេះតែមើលទៅ!

កៈ ចាស !

ខៈ សសេរទើបនិងឈប់មិញនិង!

កៈ អឺ...!

ខៈ ចម្លងធមិឲ្យយាយមួយនោះ!

កៈ ចាសចុះភាសារផ្សេងពីភាសារខ្មែរយាយចេះអត់?

ខៈ អត់ទេ អត់ចេះអីសោះហើយ(សើច)!

កៈ អឺ...!

ខៈ គ្មានបានរៀនអីទេចៅ!

កៈ អឺ...!

ខៈ កើតមកនៅជាមួយឪពុកធំនិង ដូរមកនៅនេះ ធ្វើតែស្រែនិងរួចគាត់មានលុយឯណាឲ្យរៀន

គេឲ្យហើយយើងដែរតែគាត់ថាអត់ទេ ជួយធ្វើគាត់ស្ទូងស្រូវបុកអង្ករស៊ីទៅអឺ...មហាវេទនាណាស់!

កៈ អឺ...ចុះអញ្ចឹងលោកយាយធ្វើស្រែចំការតែលោកយាយអត់ខ្មៅសោះ ស(សើច)!

ខៈ ទេមកនៅនិងទៅអត់ធ្វើអីតលូវនិងបានវាសបន្តិចនោះ!

កៈ អឺ...!

ខៈ កាលមុនខ្មៅអូញនិងណា បើដកសំណាបបោកភូសៗ!

កៈ (សើច)ការងារស្រែចំការយាយស្ទាត់ហើយ តែយូរឆ្នាំហើយយាយហ្អែរ?

ខៈ ធ្វើយូហើយចៅ !

កៈ តាំងពីមិនទាន់មានស្វាមី ដល់មានស្វាមីមានកូនទៀតន៎យាយន៎?

ខៈ ពិបាកណាស់មានប្ដីមិនដោយធម៌ទៀតនោះ!

កៈ អឺ...លោកយាយមានកូនប៉ុន្មាននាក់ដែរលោកយាយ!

ខៈ កូនបី!

កៈ គាត់ឈ្មោះអីគេខ្លះលោកយាយ?

ខៈ ឈ្មោះ សូ សាលៀង នៅអាមេរិក សូ ភី និង សូ វុធីនៅនេះ!

កៈចាស ហើយម្នាក់ទៀតលោកយាយ?

ខៈ កូនតែបីនិង!

កៈ អឺ...!

ខៈ ស្រីមួយប្រុសពីរ!

កៈ ចាសអញ្ចឹងម្នាក់ទៀតគាត់ស្លាប់នៅជំនាន់ប៉ុល ពតន៎យាយន៎?

ខៈ គ្រួសារនៅអាពត កូនអត់ស្លាប់ទេកូនបីនៅទាំងអស់ មកវិញដដែល!

កៈអូ...ល្អមែនទែន ពួកគាត់ទាំងអស់គ្នាមានប្រពន្ធមានស្វាមីហើយអស់នៅយាយ?

ខៈ មានអស់ហើយ!

កៈ អឺ...រៀបការមានចៅមានអីយាយន៎?

ខៈ (ស្ដាប់មិនបាន)!

កៈ ឥលូវមានចៅទួតនៅ?

ខៈ ចៅទួតមាននៅអាមេរិកពីរនាក់!

កៈ អឺ...ចាសយាយ បន្ទាប់មកជីវិតរបស់យាយ
នៅវត្តតាំងពីមុនមកលោកយាយមានមិត្តភក្តិស្និតស្នាលដែរឬទេយាយ?

ខ៖ មានមិត្តភក្តិយាយៗនិងឥលូវស្លាប់អស់ហើយ សល់ប៉ុន្មាននាក់ទេ!

ក៖ អឺ...គាត់?

ខ៖ ពីរនាក់បង!

ក៖ គាត់មានឈ្មោះអីខ្លះទៅយាយ?

ខ៖យាយ ឈ្មោះយាយស៊ីមហ្អែ? ស៊ន ស៊ីម មួយទៀតអីទេភ្លេចបាត់ហើយ!

ក៖ អឺ...!

ខ៖ មួយនោះឈ្មោះ នូ រ៉េត!

ក៖ ចាស ចុះយាយចាំរឿងអីខ្លះអំពីរពួកគាត់?

ខ៖ ចាស?

ក៖ កាលពីមុន យាយចាំរឿងអីខ្លះជាមួយមិត្តភក្តិយាយ មានជាមួយពួកគាត់ណា?

ខ៖ មិត្តភក្តិនិងទើបនិងស្គាល់គ្នាក្នុងវត្តនិងទេ!

ក៖ អឺ...!

ខ៖ គេនៅស្រុកគេបែកចានឯណោះ!

ក៖ ចាស!

ខ៖ យាយមួយនោះគេនៅបាត់ដឹងនោះស្រុកគេ ទើបមកពីវត្តទេបានស្គាល់គ្នានោះ!

ក៖ ចាស!

ខ៖ ហើយមិត្តភក្តិស្និតៗណានិងងាប់អស់ទៅហើយ យាយហូវយាយអីណានោះ ពីតូចមកងាប់អស់ច្រើនហើយ ពួកស្គាល់គ្នាពីតូចមក!

ក៖ ចាស!

ខ៖ ពីក្មេងៗដូចគ្នានោះ!

ក៖ ចាសយាយ!

ខ៖ ស្លាប់អស់ជំនាន់អាពត!

កៈ អឺ...សោកស្តាយមែនទែនយាយហើយលោកយាយតើលោកយាយធ្លាប់ធ្វើករអីខ្លះក្នុងជីវិតរបស់លោកយាយតាំងពីមុនមកដល់ឥលូវ?

ខៈ យាយអត់ធ្វើអីទេយាយបេះស្លឹកឈូកលក់និង ទៅបេះស្លឹកឈូកបឹងសំយ៉ាប់អីនិងទៅលក់ផ្សារថ្មីនោះ! ជូនណាទៅបេះដល់បឹងត្រាំអីនោះ ដឹកអាទះមក យកទៅបទទៅភ្លឺឡើងងើបទៅលក់!

កៈ ចាស!

ខៈ រួចពីធ្វើស្រែមកអញ្ចឹង!

កៈ ទេពីរមុខនិងទេយាយន់?

ខៈ ចាស!

កៈ ចាស!

ខៈ ដល់មានប្តីទៅលក់ចាប់ហួយ លក់ទឹក មុខរបរយាយអញ្ចឹង!

កៈ ចុះកាលពីក្មេងមកដល់សម័យឥលូវនិងជីវិតរបស់លោកយាយមានការផ្លាស់ប្តូរអ្វីខ្លះដែរ?

ខៈ ទេអត់មានផ្លាស់ប្តូរអីទេចៅ នៅតែដដែលអញ្ចឹង ដាច់ពីអាពតមកនៅវត្តជាប់ ប៉ុនឥលូវលែងរកស៊ីហើយ រកស៊ីមានបានហើយវាហិនហោចនិងអាពតអស់ហើយ!

កៈ អឺ...!

ខៈ អញ្ចឹងទៅយាយលែងរកចាស់ហើយ អត់កំលាំងរកទេ!

កៈ ចាស!

ខៈ បំរើវត្តនេះ៣០ឆ្នាំហើយ តាំងពីមកពីអាពតមក៣០ជាងហើយ!

កៈ ចាសលោកយាយ ហើយអញ្ចឹងយាយសព្វថ្ងៃយាយចូលចិត្តមុខម្ហូបអីដែរ?

ខៈថាមិច?

កៈ យាយចូលចិត្តពិសារមុខម្ហូបអីគេដែរយាយ?

ខ៖
អឺ...ចៅហើយសព្វថ្ងៃទេវតាបានលោក(ព្រះសង្ឃ)ឆាន់ហើយអស់ទៅយាយៗយកបបរមកឲ្យខក៏ខទៅ ជូនសៀងក៏សៀងទៅ ត្រសក់ស្រូវអីក៏ត្រសក់ទៅ អញ្ចឹងទេ!

ក៖ អឺ...!

ខ៖ យាយមានអីហូប កូនក្រយូរៗយកមកឲ្យម្ដង!

ក៖ អឺ...!

ខ៖ បានអីចៅហើយ វេទនាណាស់វ៉ាត់យូ(វិទ្យុ)អីនិងគេងាប់ទៅក៏ឲ្យមកទេនេះ ប្រើអានិងទៅ!

ក៖ អឺ...!

ខ៖ មើលគ្រាន់តែសុំតួបគេនៅទាំងអស់និងមានអី!

ក៖ អឺ...ចុះយាយដូចជាទាក់ទងនិងបញ្ហាខ្សែរជីវិតរបស់យាយតាំងពីមុនមកដល់ឥលូវ យាយធ្លាប់ជួបការលំបាកអីគេខ្លះដែរ?

ខ៖
អូ...ចៅហើយចៅកាលនៅពីតូចធ្វើកាលីអាៗទាពន្ធមួយថ្ងៃមួយសេនវាឲ្យរុញអាទះស៊ីម៉ង់រុញមិនរួចវាវៃៗយាយរត់លែងធ្វើម៉ង!

ក៖ អឺ...!

ខ៖ វេទនាណាស់!

ក៖ ចាសហើយពីក្មេងមកដល់ឥលូវមានធ្លាប់ចង់ធ្វើអីទេក្ដីស្រម៉ៃពីមុនមក?

ខ៖ ដឹងចង់ធ្វើអីបើឯងអត់ចេះអក្សរអត់ចេះអីផង យើងទីទាល់ក្រធ្វើមិចបាន!

ក៖ ចាសៗ!

ខ៖ យើងអត់មានតំរិះវិជ្ជាអីម្លោះហើយមានតែទូលពោតទឹកកំបោរអីលក់តែប៉ុណ្ណឹងគ្មានអីទេ!

ក៖ អឺ...ចាសអឺ...លោកយាយហើយលោកយាយចូលចិត្តលេងល្បែងអីគេខ្លះកាលនៅក្មេងៗ!

ខ៖ ខ្ញុំអត់លេងទេអត់មានសប្បាយលេងល្បែងអីនិងគេទេ មានតែដើរលក់ឪឡឹកលក់អីទៅតាមគេលេងបៀ លេងអាប៉ោង លេងឡូតូអីនិង!

កៈ អឺ...ចុះលោកយាយចូលចិត្តស្តាប់បទចំរៀងទេលោកយាយ?

ខៈ អត់ទេ!

កៈ អត់ចូលចិត្តដែរ?

ខៈចូលចិត្តស្តាប់ធម៌!

កៈ អឺ...កាលពីមុនៗណាយាយៗចូលចិត្តស្តាប់ទេ?

ខៈ ពីក្មេងអត់មានស្អីផងថៅ បើគេមានបុណ្យអីនិងវត្តទៅកុនអីមកមើលគេទៅយប់ៗ!

កៈ អឺ...!

ខៈ មានអីលេងពីដើម!

កៈ ចាស!កាលនិងកុនអីដែរយាយ ចូលចិត្តមើលកុនអីដែរ?

ខៈកុនអាគេដាក់កក្រដាសនិងក្រណាត់និងមើលតែអានិងរោងគេអត់ទៅទេ!

កៈអឺ...ចាសចុះនរណាកេនៅក្នុងសមាជិកគ្រួសាររបស់យាយចេះលេងភ្លេងយាយដឹងទេ?

ខៈ អត់!

កៈ អត់មានទេយាយន៎?

ខៈ អត់ទេមានតែកូនមួយប្រុសគេចូលយាយស៊ូគេមានចាប៉ីគេដេញ!

កៈ ប្តីតាតើយាយ?

ខៈ និងហើយ!

កៈ អឺ...!

ខៈ យាយអត់មានចូលចិត្ត!

កៈ អឺ...អញ្ចឹងពេលយាយពិបាកចិត្តម្តងៗយាយធ្វើមិចទៅយាយ?

ខៈ ពិបាកចិត្តមានព្រះធម៌ទៅថៅហើយអត់មានអីទេ !

កៈ ស្តាប់ធម៌ស្តាប់អីអញ្ចឹងទៅយាយន៎?

ខ៖ របស់អស់និងវាអត់មានបានខ្លឹមសារអីទេ!

ក៖ អឺ...!

ខ៖ អាអ្នកលេងកុនក៏ពិបាក យាយទៅមើលម្តងដែរ ហើយនាង(ស្តាប់មិនបាន)ខាងលិចផ្សារថ្មីនិងពីដើមវាវាល ទៅមើលតែមួយយប់និង!

ក៖ ចាស អញ្ចឹងផ្ទះរបស់យាយវិញមានលក្ខណៈមិចដែរ? តាំងពីយាយនៅពីតូចមក កាលពីមុនណា?

ខ៖ ផ្ទះហ្អែស?

ក៖ ចាស!

ខ៖ កន្លែងផ្ទះនិង អាកន្លែងផ្ទះដែលចេញទៅឃើញផ្ទះថ្មរនិង ផ្ទះយាយអានេះយាយចែកឲ្យអានៅអាមេរិកនោះអី អាលូវគេធ្វើផ្ទះថ្មរ ៗលិចទឹកទៀតន៎!

ក៖ អឺ...!

ខ៖ មកនៅផ្ទះនិង មកពីអាពតនិង!

ក៖ អឺ...ចាសហើយដីនិងវគ្គគេឲ្យឬក៏យាយចាប់នៅតែម្តង ?

ខ៖ ដីនិងទិញគេតើពីសង្គមមក!

ក៖ទិញប៉ុន្មានយាយ?

ខ៖ មួយម៉ឺន៥ពាន់ពីដើមថោកទេ!

ក៖ អឺ...ធំដែរទេយាយ?

ខ៖ មានអីធម្មតា!

ក៖ អឺ...ចុះអីលូវដីផ្ទះនិង?

ខ៖ចែកឲ្យទៅកូនអស់ហើយ!

ក៖ អឺ...!

ខ៖អត់មានដីទេ អស់ហើយ
ឥលូវកូននិងនៅដីគៀនវត្តនិងគេគិតធ្វើថ្នល់ទៀតរកដីនៅមិនបានផងកូន!

ក៖ អឺ…!

ខ៖ ឯងមកគេយកដីអស់ហើយ
ឯងរកយកដីឯងគេថាអូ…ទុកដាក់ឈើពួកអាប្រធានភូមិនោះរួចទៅវានាំគ្នាលក់
ដីឯងធ្វើចំការធ្វើអី ជិតម៉ុងខ្មោចអីអត់សល់ទេនាង ទៅទល់ថ្នល់អាទះភ្លើង
ទៅទល់បឹងប្រយ៉ាប ពេទ្យលោកសង្ឃ!

ក៖ចាស!

ខ៖ យ៉ាប់ណាស់!

ក៖ ចាស !

ខ៖ ឆ្ងាយអត់អីទេ!

ក៖ ចាស អញ្ចឹងយាយការកសាងផ្ទះនិង យាយជួលគេក៏ធ្វើខ្លួនឯង?

ខ៖ ធ្វើខ្លួនឯងហើយទិញឈើជួលជាងធ្វើ!

ក៖ អូ…យាយពូកែណាស់ធ្វើខ្លួនឯង!

ខ៖ ធ្វើខ្លួនឯងទិញឈើមកជួជាងធ្វើហើយយាយអាលែងលក់ចាប់ហួយៗជួលទៃគេធ្វើទៅ!

ក៖ អឺ…កាលនិងស្វាមីរបស់យាយអីជួយដែរទេឬក៏?

ខ៖ ចាស ជួលគេធ្វើទៅប៉ុន្មាន អស់ប៉ុន្មានទៅយើងគ្រាន់តែមើលទៅ ខ្វះឈើទិញឈើ
ខ្វះដែកគោលទិញដែកគោល!

ក៖ អឺ…ហើយសម្ភារៈធ្វើផ្ទះនិងឈើអីៗដែរយាយ?

ខ៖ ធ្វើផ្ទះនិងឈើ ហើយធ្វើអាមុខអញ្ចែកមិនទេអាធ្វើអាប៊ីឡូឈើ!

ក៖ អឺ…ៗអញ្ចឹងលោកយាយជឿព្រះពុទ្ធសាសនាអ្នកជាពុទ្ធបរិស័ទ្ធហើយយាយន៎?

ខ៖ ចាស!

ក៖ យាយកាន់ព្រះពុទ្ធសាសនាអញ្ចឹងយាយកាន់ពុទ្ធសាសនារយះពេលប៉ុន្មានហើយ?

ខ៖ យូហើយតាំងពីមកអាពតថៅឯងមើល៣០ប៉ុន្មានឆ្នាំហើយ!

ក៖ ចាស!

ខ៖ មុនទៅអាពតក៏យាយកាន់ពុទ្ធសាសនាហើយយាយអត់មានចូលសាសនាណាទេ!

ក៖ ក្រុមគ្រួសារយាយទាំងអស់ជឿលើពុទ្ធសាសនាទាំងអស់យាយន៎?

ខ៖ ចាស!

ក៖ ចុះមូលហេតុអីដែរលោកយាយជឿលើពុទ្ធសាសនា?

ខ៖ មានមួយវាជឿលើយាយស៊ូឥលូវនិងនោះ!

ក៖ អឺ...!

ខ៖ អាមួយនៅជាប់ល្បងវត្តនោះ ប្រពន្ធគេយាយស៊ូប្តីគេចូកដៃរទៅ
ថាកុំឲ្យទៅរៀនប្រយត្ន័ចូលយាយស៊ូ
អត់ទេម៉ែខ្ញុំគ្រាន់តែទៅរៀនអាអង់គ្លេសឲ្យចេះព្រោះគេអត់យកលុយ
ដល់ចូលទៅគេបានប្រពន្ធនិងទៅគេទៅនិងទៅ វាមានមកស្តាប់យើងអីសព្វថ្ងៃ!

ក៖ អឺ...ចុះយាយគិតថាការកាន់ព្រះពុទ្ធសាសនា ជួយយាយអីខ្លះដែរ?

ខ៖អត់ជួយអីទេគ្រាន់មានជឿបុណ្យនិងបាប!

ក៖ និងហើយ!

ខ៖ ព្រះអង្ឃមានជួយអីទេ!

ក៖ អប់រំផ្លូវចិត្តយាយ!

ខ៖ ចាស!

ក៖ ធ្វើឲ្យចិត្តយាយមិចដែរយាយ?
ដូចជាពេលមុនយាយមិនទាន់ជឿដល់ពេលឥលូវាយាយជឿអញ្ចឹងធ្វើឲ្យជីវិតយាយមិចដែរយាយ?

ខ៖ ឲ្យវាទៅតាមយថាកម្មទៅ យើងធ្វើបុណ្យបានបុណ្យ ធ្វើបាបបានបាបទៅ!

ក៖ អឺ...!

ខ៖ ពុទ្ធសាសនាអញ្ចឹង!

ក៖ អប់រំផ្លូវចិត្តយាយឲ្យ!

ខ៖ ចាស!

ក៖ កុំឲ្យលោភលន់អីបានប៉ុណ្ណា ប៉ុណ្ណឹងទៅ!

ខ៖ និងហើយ!

ក៖ ចាស អញ្ចឹងអ៊ី...ទាក់ទងនិងបញ្ហាជីវិតលោកយាយមានការលំបាកអីពីមុនយាយបានប្រាប់ហើយតែមកដល់ឥលូវនេះយាយអាចមានដូចជាបទពិសោធន៍ល្អៗដែលនិងចាំមកយាយសប្បាយចិត្តដែរឬទេ?

ខ៖ ខ្ញុំមានតែថ្វាយបង្គំព្រះមានតែធ្វើបុណ្យទេខ្ញុំអត់មានធ្វើអីទេ!

ក៖ អ៊ឺ...ចាសអញ្ចឹងយាយមានបទពិសោធន៍ល្អៗរឿងដែលធ្វើឲ្យយើងសប្បាយចិត្តណា?

ខ៖ ទេកើតមកមួយជាតិនេះអត់មានសប្បាយចិត្តសោះ បើទុក្ខគ្មានម៉ែគ្មានឪគ្មានបងគ្មានប្អូនបានអីសប្បាយទៅ ខ្ញុំអត់មានសប្បាយទេ!

ក៖ អ៊ឺ...ចាសយាយ!

ខ៖ ថ្ងៃនិងថ្ងៃអីតេជគុណ!

ក៖ ថ្ងៃនេះថ្ងៃអង្គារយាយ!

ខ៖ ចាស?

ក៖ ថ្ងៃអង្គារយាយ!

ខ៖ ថ្ងៃអង្គារប៉ុន្តែក្រែងលោថ្ងៃកោអីទៅណា!

ក៖ អ៊ឺ...លោកយាយជាចុងក្រោយលោកយាយមានពាក្យពេជ្យអីសំរាប់ផ្តាំផ្ញើរទៅដល់កូនចៅជំនាន់ក្រោយ?

ខ៖ អ៊ឺ...ដឹងបានអីទេចៅអើយមានតែកូនចៅខំធ្វើបុណ្យធ្វើទានទៅតែប៉ុណ្ណឹងធ្វើបុណ្យទៅយើងបានទៅជាតិក្រោយទៅវារួចចាកទុក្ខ និងដឹងគុណមាតាបិតា!

កៈ ចាសយាយ!

ខៈ មានតែគុណមាតាបិតានិងហើយដែលខំបង្កើតយើងមក!

កៈ ចាសៗ!

ខៈ មានកូនដែលវាមិនដឹងគុណមានចៅខ្ញុំមួយវាមិនដឹងគុណម៉ែឪ
អានិងកូនស្រីមួយកូនមេម៉ាយ ខ្លួនមេម៉ាយមានកូនប្រុសតែមួយប្រដៅអត់បានទេ បំផ្លាញ
ដើរផឹកដើរស៊ី ឥលូវបឈឺក្រពះហើយ!

កៈ អឺ...!

ខៈ អាយុ២៥សោះរៀនអតើរៀនទេ យកទាលុយដើរលេងតាមពួកម៉ាក!

កៈអឺ...!

ខៈ រួចដល់អញ្ចឹងយាយបានអីសប្បាយចិត្តចៅគិតមើល!

កៈ ចាស!

ខៈ អាណិតម៉ែ អាណិតមីកូនស្រីនិងមួយថ្ងៃវាទាមួយម៉ឺនរាល់ថ្ងៃនិងហា ហើយវាអត់ធ្វើការ
ម៉ូតូអស់ពីរបីហើយបំផ្លាញឥលូវបញ្ចាំផ្ទះឲ្យគេទៀត!

កៈ អឺ...!

ខៈ បញ្ចាំផ្ទះយកលុយទិញម៉ូតូឲ្យវា
ទៅធ្វើការធ្វើបានតែមួយថ្ងៃពីរទៅវាឈឺក្រពះវាអត់ទៅធ្វើទេ!

កៈអឺ...!

ខៈ រកលុយរាប់ឲ្យគេមិនទាន់បានផង បានអីសប្បាយចៅយាយយ៉ាងនិងទុក្ខយ៉ាងនិង
កើតមកមួយជាតិនេះ យាយគ្មានចង់រស់អិបន្តិចទេពិបាកចិត្តពេក
កូនទៅអាមេរិកគេចិញ្ចឹមមួយខែ១០០(ដុល្លា)ស៊ីវាមិនគ្រាន់ទេមួយខែ១០០និង
ថ្នាំផឹកសព្វថ្ងៃស៊ីបាយវត្តធ្វើបុណ្យបន្តិចបន្តួចទៅ ថ្នាំៗ!

កៈ អឺ...យាយឈឺអីខ្លះដែរយាយ?

ខៈ យាយទឹកនោមផ្អែមពុកឆ្អឹងៗ!

កៈ ពុកឆ្អឹង!

ខៈ ពុកឆ្អឹង
ស្បូនកាត់រួយហើយៗហើយចុះហេតុអីបានជាវានៅឈឺក្នុងនិងឈឺចាក់ថ្នាំមួយថ្ងៃ១២ដុល្លាង
ណោះមួយថ្ងៃ១២ដុល្លាចាក់អត់បាត់លែងចាក់ហើយ!

កៈ អឺ...!

ខៈ អាថ្នាំទឹកនោមផ្អែមលេបជាប់រាល់ថ្ងៃមួយបន្ទះ១៨០០០!

កៈ អឺ...!

ខៈ ហើយអាថ្នាំលើសឈាម នៅអាថ្នាំជាតិស្ករឡើងទៀត
ជាតិស្ករឡើងដល់៨០ហើយ៨៧២សព្វថ្ងៃ!

កៈ អឺ...!

ខៈ រួចបានអីសប្បាយមើលគិតមើលៗរួចចុកអស់ហើយ
អត់មានអ្នកណាជួយច្របាច់អីចុកៗក្នុងឆ្អឹងនិងចុកជើងនិងដើររកតែដួលអានេះវាចាក់ពីនេះ
ទៅទៅដល់បាតជើង ដេកមិនលក់អីម៉ោងមួយម៉ោងពីរាល់តែថ្ងៃនិង!

កៈ អឺ...!

ខៈ បានអីសប្បាយអត់មានទេមានតែទុក្ខ បើគិតតែងាប់ៗ!

កៈអឺ...!

ខៈ ម្រាមដៃឈឺទាំងម្រាមដៃ ម្រាមជើងអាខាងនេះក៏ឈឺ
ៗអាត្រង់ឆ្អឹងទាល់តេលាបប្រេងកូឡាទៅអន់ទៅលាបពីក្រៅពីក្នុង
អត់មានសប្បាយទេចៅអើយកើតមកវេទនាណាស់
បែរតែធ្មេញនេះអស់ហើយរកតែអីដាក់មិនបាននៅតែអាលើនិង!

កៈ (សើច)តែធ្មេញយាយនៅមាំណាស់ យាយ?

ខៈ នៅអត់រង្គើរទេឆ្ងល់ដែរ អត់រង្គើរទេតែអាក្រោមវាបាក់!

កៈ ចាស!

ខ៖ស៊ីទៅធ្លាក់បាយក្តុក!

ក៖ អឺ...!

ខ៖ វេទនាយ៉ាងនិងអញ្ចឹងឯងបានអីសប្បាយ
វាឈឺក្នុងអាស្បូននេះស្បូននិងចាប់ៗទិញទឹកកកមកស្អំក៏មិនបាត់អាស្អីក៏មិនបាត់ដែរ!

ក៖ ចុះកាលនិងមិចក៏យាយកាត់ស្បូនចោលអញ្ចឹង?

ខ៖ ទៅអាពតនិងវាស្រុតប្រវែងនេះចៅ!

ក៖ អឺ...!

ខ៖ យាយចេះតែខ្មាសគេ!

ក៖ កាលនិងយាយកើតកូននៅជំនាន់អាពតហ៎?

ខ៖ កើតមកពីអាពតបានម៉ាឆ្នាំពីរ!

ក៖ អឺ.. ចាសយាយ!

ខ៖ វេទនាណាស់ចៅហើយ!

ក៖ ចាស!

ខ៖ ភ្នែកនេះទៅវះហើយនៅតែស្រវាំងឡើងពីរជាន់ ភ្នែក
ឥលូវដូចវាអស់ហើយចៅអើយអាច្រដៀកក៏វាថ្លង់គ្រប់មុខអស់ហើយ វាចុកវាចាប់ទៅ
ច្របាច់ខ្លួនឯងនិងមានកូនណាមកជួយទេតប់អីខ្លួនឯងអញ្ចឹងទៅយកព្រេងដូងមករិត
ចៅអើយចៅវេទនាណាស់ ប្រេងដូងប្រេងកូឡានិង!

ក៖ ចាសចុះវាអត់មានធូអីទេយាយន៎លេបថ្នាំលេបអីទៅ!

ខ៖ អន់ម៉ាអំណាចថ្នាំនិងហា កាលណាលេបទៅវាអន់ទៅ ថ្នាំឆ្នាំងផឹកទៀតមួយកញ្ចប់២ម៉ឺន
ផឹកថ្នាំឆ្នាំកុំវាឈឺក្រលាក់ដៃក្រលាក់ជើងអីនិង!

ក៖ ចាស!

ខ៖ នៅតែឈឺ ចុកយក ដឹងធ្វើមិចមាននរណាគេជួយយើងបាន
ងាប់ខ្លួនឯងរស់ខ្លួនឯងឈឺខ្លួនឯងហើយកូនណាក៏វាជួយយើងមិនរួចដែរ!

ក៖ អឺ...!

ខ៖ ចាស់ទៅវេទនាណាស់ចៅអើយ!

ក៖ អញ្ចឹងលោកយាយមានពាក្យពេជ្យអីដើម្បីផ្តាំផ្ញើរជាចុងក្រោយទៀតទេយាយ?

ខ៖
អើយកូនចៅនៅខាងក្រោយបានសុខបានចំរើនខំធ្វើបុណ្យធ្វើទានរក្សារសីលទៅគ្មានស្អីយកទៅរួចទេលុយយកទៅមិនរួចខោអាវក៏យកទៅមិនរួចដែរគេដុតខ្ទេចខ្ទីអស់ហើយ
គ្មានយកអីទៅរួចទេមានតែបុណ្យទេយកទៅតាមខ្លួនបើអត់បុណ្យទេមានតែបាប នរកហើយ!

ក៖អឺ...!

ខ៖ មានប៉ុណ្ណឹងចៅយាយផ្តាំផ្ញើរតែប៉ុណ្ណឹងទេ!

ក៖ ចាសយាយៗ អញ្ចឹងអគុណច្រើនសំរាប់ការសម្ភាសថ្ងៃនិង
អញ្ចឹងតើលោកយាយអនុញ្ញាតិឲ្យចៅដាក់សំលេងរបស់យាយរូបថតរបស់យាយនៅក្នុងវែបសាយរបស់ខាងសាលាដែរទេ?

ខ៖យករូបថតទៀត?

ក៖ អត់ទេរូបថតចៅថតមុននិងមិញណាយាយ!

ខ៖ ចាស!

ក៖ ថតហើយមុននិងមិញយាយ!

ខ៖ ចាសដាក់ទៅចៅ!

ក៖ ចាសអគុណច្រើនយាយសំរាប់ថ្ងៃនិងដែលចំណាយពេលឲ្យចៅក្នុងការសម្ភាស!